ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា**
**ប្រចាំនៅទីក្រុងណាននីង**

**លេខ** 00132 **កពណក.ណន** **សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ: របាយការណ៍ ប្រចាំខែកញ្ញា ឆ្នាំ២០១២**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំ ខែកញ្ញា ឆ្នាំ២០១២ ។

## I. ជួបជាមួយភ្ញៀវ

- ជួបក្រុមហ៊ុន Guangxi Nanning Zhonglei Stone Co., Ltd. មានបំណងវិនិយោគដាំដំឡូងនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Ningxia KailiteHuagongYouxiangGongsi. មានបំណងស្វែងរកដៃគូរនិងស្វែងរកទីផ្សារលក់ជីគីមីនៅកម្ពុជា ។
- ជួបក្រុមហ៊ុន QIRUI COATINGS មានបំណងវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេស SEZ នៅក្រុងព្រះសីហនុ និងស្វែងរកដៃគូលក់ថ្នាំលាបផ្ទះនៅកម្ពុជា ។
- ជួបក្រុមហ៊ុន Guangxi Zhengwu Marine IndustryCo., Ltd. មានបំណងស្វែងរកដៃគូក្នុងការនាំចេញផលិតផលសមុទ្រពីកម្ពុជា ។
- ជួបក្រុមហ៊ុនផលិតថ្នាំបសុសត្វមានបំណងវិនិយោគនៅកម្ពុជា និងមានបំណងស្វែងយល់វិស័យអាទិភាពក្នុងការប្រកបអាជីវកម្មនៅកម្ពុជា ។
- ទទួលនិងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** ទៅចូលរួមពិពរណ៍ពាណិជ្ជកម្មចិន-អាស៊ាន លើទី៩ នៅក្រុងណាននីង ចាប់ពី ថ្ងៃទី ២១-២៥ ខែកញ្ញា ឆ្នាំ២០១២ ។
- ទទួលនិងជូនដំណើរគណៈប្រតិភូក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល មកចូលរួមសិក្ខាសាលានៅក្រុងណាននីង ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០១២ លើប្រធានបទ " Cooperative Exploitation and Sustainable Development of Greater Mekong Sub-region(GMS) Resources" ។

## II. ការតាំងពិពរណ៍ពាណិជ្ជកម្ម(CAEXPO)នៅក្រុងណាននីង

នៅក្នុងឆ្នាំ២០១២នេះព្រឹត្តិការណ៍ដែលលេចធ្លោជាងគេនៅណាននីង គឺការរៀបចំ **ពិពរណ៍ពាណិជ្ជកម្មចិន_អាស៊ាន(CAEXPO)** ខួបលើកទី៩ និងជាខួបលើកទី២នៃតំបន់ពាណិជ្ជកម្មសេរី (CAFTA) ហើយជាខួបលើក

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com

ទី១០ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ចិន-អាស៊ាន ។ ជារៀងរាល់ឆ្នាំក្រសួងពាណិជ្ជកម្មដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានដឹកនាំពាណិជ្ជករ ឧស្សាហករកម្ពុជា មកចូលរួមពិព័រណ៍ពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយផលិតផលកម្ពុជា និងស្វែងរកដៃគូពាណិជ្ជកម្ម ។ នៅក្នុងឆ្នាំ២០១២នេះ ពិព័រណ៍ពាណិជ្ជកម្ម ចិន-អាស៊ាន លើកទី៩ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១-២៥ ខែកញ្ញា ឆ្នាំ២០១២ ។ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ គណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** ដែលជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានចូលរួមសម្ពោធពិព័រណ៍ខាងលើនៅមជ្ឈមណ្ឌលពិព័រណ៍អន្តរជាតិ ចិន-អាស៊ាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម Xi Jinping** អនុប្រធានាធិបតីចិន ។ បន្ទាប់ពីបើក សម្ពោធពិព័រណ៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានចូលរួម **ប្រជុំកំពូលធុរកិច្ចនិងវិនិយោគចិន-អាស៊ាន លើកទី៩** (CABIS) នៅសាលប្រជុំនាសណ្ឋាគារលីយ៉ន់ ក្រុងណាននីង ។ នៅល្ងាចថ្ងៃដដែល **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក្នុងនាមជា **រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន** បានចូលរួមវេទិកាការតំបន់ពាណិជ្ជកម្មសេរី ចិន-អាស៊ាន ឆ្នាំ២០១២ ក្រោមប្រធានបទ **"ពង្រឹងកិច្ចសហប្រតិបត្តិការស៊ីជម្រៅនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងឈានទៅរកសមាហរណកម្មកំរិតខ្ពស់"** "**Promoting deeping cooperation & sustainable Development forward a higher level of Integration**" ដោយវត្តមាន **ឯកឧត្តម** Supachai Panitch Padi **អគ្គលេខាធិការអង្គការ** UNTAD និង **ឯកឧត្តម** Lim HongHin **អគ្គលេខាធិការអាស៊ាន** ប្រចាំក្រុងហ្សាការតាប្រទេសឥណ្ឌូនេស៊ី ។ នៅឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី**បានធ្វើបទឧទ្ទេសនាមមួយដោយបានបញ្ជាក់ថា សិក្ខាសាលាឆ្នាំនេះមានលក្ខណៈពិសេស ពោលគឺខួបលើកទី១០នៃការចុះហត្ថលេខា កិច្ចព្រមព្រៀងសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយចិន-អាស៊ាន និងជាខួបលើកទី២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចិន-អាស៊ាន ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងលើចំណុចសំខាន់ៗ ចំនួន០៣ដូចតទៅ :

១- ឱកាសទទួលបានការសំរេចកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចិន-អាស៊ាន ។

២- ភាពប្រឈមមុខនានា ។

៣- សមាហរណកម្មសរុប ពោលគឺការប្រមូលផ្តុំកម្លាំងសេដ្ឋកិច្ចរឹងមាំចិន-អាស៊ាន និងការប្តេជ្ញាសមាហរណកម្ម សេដ្ឋកិច្ចកំរិតខ្ពស់ ដោយកាត់បន្ថយគំលាតនៃការអភិវឌ្ឍន៍ ។

បន្ទាប់ពីចូលរួមសិក្ខាសាលាខាងលើរួចមក **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានធ្វើបទសំភាសន៍ជាមួយអ្នកសារពត៌មាន ដែលមានបំណងស្វែងយល់ទំនាក់ទំនងចិន-អាស៊ាន ជាពិសេសចិន-កម្ពុជា និងស្វែងយល់នូវសក្តានុពលរបស់កម្ពុជា និងទីផ្សារនាំចេញ ។ នៅទីបញ្ចប់អ្នកសារពត៌មានបំណងស្វែងយល់ការបញ្ចូល**ហុងកុង**ទៅក្នុងតំបន់ពាណិជ្ជកម្មសេរី ចិន-អាស៊ាន ។

ឆ្លើយតបនូវសំនួរខាងលើ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ថាទំនាក់ទំនងចិន-អាស៊ានបានឈានដល់កិច្ចសហប្រត្តិបត្តិការគ្រប់ជ្រុងជ្រោយ ជាពិសេសតំបន់ពាណិជ្ជកម្មសេរី ចិន-អាស៊ាន(CAFTA) បានចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០មកម្ល៉េះ ។ ចិនជាដៃគូចាត់ចំណាត់ថ្នាក់ទី១របស់អាស៊ាន ។ នៅក្នុងឆ្នាំ២០១០ កន្លងទៅនេះ ការផ្លាស់ប្តូរពាណិជ្ជកម្មចិន-អាស៊ាន កើនបាន២០,៩% ពោលគឺកើនពី ២៣២ ពាន់លានដុល្លា ទៅ ២៤០,៤

ពាន់លានដុល្លាក្នុងឆ្នាំ២០១១កន្លងទៅនេះ ។ដោយឡែកលំហូរវិនិយោគចិនទៅប្រទេសអាស៊ាននៅក្នុងឆ្នាំ២០១០កើនបាន ១១៧% ស្មើនឹង ២,៧ ពាន់លានដុល្លា ឯនៅក្នុងឆ្នាំ២០១១ កើនបាន ៥,៩ ពាន់លានដុល្លា។ កម្ពុជា ជាប្រទេសកសិកម្មអន់ថយ តែទទួលភាពអនុគ្រោះពាណិជ្ជកម្មពីបណ្តាប្រទេសអភិវឌ្ឍន៍និងប្រទេសជាដៃគូជាច្រើន ដោយរាល់ទំនិញនាំចេញពីកម្ពុជាត្រូវបានអនុគ្រោះពន្ធគយ ។ សក្តានុពលរបស់កម្ពុជាគឺកានាំចេញ អង្ករ កៅស៊ូ ផលិតផលរោងចក្រកាត់ដេរ និងកសិផលដទៃទៀត ។ ដោយឡែកការងារទំនាក់ទំនង ចិន-កម្ពុជា គឺជាការទំនាក់ទំនងជាយុទ្ធសាស្ត្រ និងសហប្រត្តិបត្តិការគ្រប់ជ្រុងជ្រោយ ។ ក្នុងការជំនួបថ្នាក់ដឹកនាំប្រទេសទាំងពីរបានកំណត់ការផ្លាស់ប្តូរ ពាណិជ្ជកម្ម ចិន-កម្ពុជា ឱ្យកើនបាន ៥០០០លានដុល្លាអាមេរិក នៅក្នុងឆ្នាំ២០១៧ខាងមុខនេះ ។ ដោយឡែក បន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចនៅក្នុង ពិភពលោកទីផ្សារអចលនទ្រព្យនៅកម្ពុជាកំពុងងើបឡើងវិញ ។ ចំពោះការស្នើសុំឱ្យ**ហុងកុង**ចូលក្នុងតំបន់ពាណិជ្ជកម្មសេរី ចិន-អាស៊ាន នោះ សមាជិកអាស៊ានទាំងអស់កំពុងពិនិត្យពិភាក្សាដែលមាន ការពាក់ព័ន្ធក្របខណ្ឌច្បាប់ និងលក្ខណ្ឌក្នុងការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ។ ក្នុងឱកាសស្នាក់នៅក្រុងណាននីង **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជួបសំដែងការគួរសមជាមួយ **ឯកឧត្តម Guo Shengkun** ជាលេខាបក្សខេត្ត និង **ឯកឧត្តម Ma Biao** អភិបាលតំបន់ស្វយ័តក្វាងស៊ី ។ យោងតាមការអញ្ជើញរបស់ ឯកឧត្តមអភិបាលក្រុង **Liuzhou** **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានដឹកនាំគណៈប្រតិភូទៅចូលរួមពិពរណ៍ **“2nd China-ASEAN (Liuzhou) Automobiles, construction, Equipment, Component & Part Expo”** ។ នៅល្ងាចថ្ងៃដដែល **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានទៅទស្សនារោងចក្រផលិតដែក បន្ទាប់មកទៅទស្សនាសារមន្ទីរ និងទស្សនាក្រុមហ៊ុន **Liang Miannzhen C., Ltd.** ដែលផលិតសំភារៈប្រើ ប្រាស់ប្រចាំថ្ងៃ ។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២ គណៈប្រតិភូកម្ពុជាដឹកនាំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងជោគជ័យ ។

សេចក្តីដូចបានជំរាបជូនខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ២០១២ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ក្រុងណាននីង, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១២

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គីមយ៉ុន**

<u>ចម្លងជូន</u>

-អគ្គកុងស៊ុលនៅណាននីង

-ឯកសារកាលប្បវត្តិ